# សាលា ANDREW JACKSON
## 1213 S. 12TH STREET
## PHILADELPHIA, PA 19147

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤

ជូនចំពោះ មាតាបិតា/អាណាព្យាបាល៖

ដោយសេចក្តីក្រៀមក្រំយ៉ាងខ្លាំង ខ្ញុំសូមជម្រាបលោកអ្នកអំពីមរណភាពយ៉ាងឆាប់រហ័ស របស់សិស្សថ្នាក់ទី១របស់យើងម្នាក់ ។ យើងខ្ញុំចង់ជម្រាបលោកអ្នកថា ក្រុមជំនួយផ្នែក ភាពអាសន្ន/វិបត្តិ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា កំពុងផ្តល់ឱវាទដល់ក្មេងនៅសាលារបស់យើងខ្ញុំនៅថ្ងៃនេះ។ ក្រុមអ្នកផ្តល់ឱវាទផ្នែកទុក្ខព្រួយ បាននិយាយជាមួយក្មេងម្នាក់ៗ និងតាមក្រុមតូចៗ ទៅតាមសេចក្តីត្រូវការ។

ការបាត់បង់ជីវិតយ៉ាងឆាប់រហ័សបែបនេះ អាចមានការប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់សិស្សានុសិស្សរបស់យើង។ ដោយមូលហេតុនេះ យើងខ្ញុំសុំឲ្យលោកអ្នកស្តាប់កូន ព្រមទាំងពិភាក្សាជាមួយពួកគេអំពី អារម្មណ៍របស់ពួកគេ និងប្រតិកម្មរបស់ពួកគេទៅនឹងការបាត់បង់ជីវិតនេះ។ ការបាត់បង់ជីវិតយ៉ាងឆាប់រហ័ស គឺជាការឈឺឆាប់ដែលយើងពិបាកកាត់យល់ ហើយកូនលោកអ្នកប្រហែលជាបង្ហាញសញ្ញានៃការពិបាកចិត្ត។ សញ្ញាមួយចំនួនដូចជា៖

- មិនអាចផ្តោតអារម្មណ៍
- ឆាប់ខឹង ឬ បង្កើនការមួម៉ៅ
- ឯកោ មិនចូលរួមក្នុងសកម្មភាព និង ជាមួយមិត្តភ័ក្ត
- បន្ទោសខ្លួនឯង
- ភ័យខ្លាច និង ខ្វល់ខ្វាយ
- មានការផ្លាស់ប្តូរក្នុងការ គេង ឬចំណង់អាហារ

បើសិនជាលោកអ្នកឃើញកូនផ្លាស់ប្តូរ អាកប្បកិរិយា ឬ មនោសញ្ចេតនា ខុសពីធម្មតា សូមទាក់ទង **សាលា Andrew Jackson** លេខ ២១៥-៩៥២-៦២២៣ ដើម្បីទទួលជំនួយបន្ថែម។ សូមទូរស័ព្ទមកយើងខ្ញុំ បើសិនជាលោកអ្នកមានសំណួរអ្វី។ ព័ត៌មានបន្ថែមមាននៅទំព័រម្ខាងទៀត នៃលិខិតនេះ។

ដោយសេចក្តីស្មោះស្ម័គ្រ

Lisa Ciaranca-Kaplan
នាយិកាសាលា